00293390

**Declassified to Public**
**06 September 2012**

E28/3

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងព្រហ្មទណ្ឌលេខ: | ០០១/១៨-០៧-២០០៧-អវតក/អជសដ |
| ដាក់តម្កល់ជូន: | អង្គជំនុំជម្រះសាលាដំបូង |
| កាលបរិច្ឆេទដាក់ឯកសារ: | ២៧/០៣/២០០៩ |
| ភាគីអ្នកតម្កល់: | មេធាវីលោក កាំង ហ្គេកអ៊ាវ |
| ភាសាដើម: | ភាសាបារាំង |
| ប្រភេទឯកសារ: | សាធារណៈ |

## សេចក្តីបញ្ជាក់របស់ក្រុមសហមេធាវីការពារក្តី នៅលើបញ្ជីឈ្មោះសាក្សី ដែលបង្ហាញដោយ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្រុម ១

**អ្នកដាក់តម្កល់:**

សហមេធាវី

កាំង ហ្គេកអ៊ាវ

លោក ការ សាវុត

លោក François ROUX

**តម្កល់ជូន:**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម ធូ មណី

**ចម្លងជូន:**

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

**ចម្លងជូន:**

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

មេធាវី គង់ ពិសី

មេធាវី ហុង គឹមសួន

មេធាវី យុង ផានិត

មេធាវី គីម ម៉េងឃី

មេធាវី ម៉ុច សុវណ្ណារី

Me Silke STUDZINSKY
Me Martine JACQUIN
Me Philippe CANNONE

មេធាវី ទី ស្រីនណា

Me Pierre Olivier SUR
Me Alain WERNER
Me Brianne McGONIGLE
Me Annie DELAHAIE
MeElizabethRABESANDRATANA
Me Karim KHAN

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 03 / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 31 / 03 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

00293391

[០០១/១៨-០៧-២០០៧-អវតក/អជសជ]

E28/3

## គោរពជូនអង្គជំនុំជម្រះសាលាដំបូង

### I. សេចក្ដីផ្ដើម

១. ក្រុមសហមេធាវីការពារក្ដី បានដាក់តម្កល់រួចមកហើយកាលពីថ្ងៃទី ២៤ ខែមីនា ឆ្នាំ ២០០៩ នូវចម្លើយតបទៅនឹងបញ្ជីសាក្សី និងឯកសារទាំងឡាយដែលដាក់តម្កល់ដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម ១ ជាភាសាខ្មែរ និងជាភាសាបារាំង [1]។

២. នាថ្ងៃដដែលនោះ ក្រុមសហមេធាវីការពារក្ដី បានទទួលនូវលិខិតជូនដំណឹងអំពីសេចក្ដីណែនាំស្ដីពីបញ្ជីសាក្សី និងអ្នកជំនាញរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ និង ក្រុម៣" [2]។

៣. នៅក្នុងសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ទៅក្រុមសហមេធាវីការពារក្ដី *"ឲ្យធ្វើការបញ្ជាក់ យោងទៅលើបញ្ជីសាក្សីដែលដាក់តម្កល់ដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ក្រុម១ ថាតើសំណើររបស់ខ្លួនក្នុងអំឡុងសវនាការបឋមសុំឲ្យកោះហៅលោក* ***Robert BADINTER*** *ឲ្យមកថ្លែងអំពីតួនាទីរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីនោះ គឺជាការឆ្លើយតបទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការកោះហៅសាក្សី* ***Christopher STAKER*** *"* [3]។

៤. ក្នុងការឆ្លើយតបទៅនឹងសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះ ក្រុមសហមេធាវីការពារក្ដីសូមធ្វើការបញ្ជាក់បន្ថែមដូចមានជម្រាបជូនខាងក្រោមនេះ។ ក្រុមសហមេធាវីការពារក្ដី នឹងធ្វើការឆ្លើយតប

---

[1] ឯកសារលេខ E28/1

[2] សូមពិនិត្យមើល *"សេចក្ដីណែនាំស្ដីពីបញ្ជី សាក្សី និងអ្នកជំនាញរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ និង ក្រុម៣"* អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ថ្ងៃទី២៣ ខែមិនា ឆ្នាំ ២០០៩ (E28)។

[3] សូមពិនិត្យមើល *"សេចក្ដីណែនាំស្ដីពីបញ្ជី សាក្សី និងអ្នកជំនាញរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្រុម១ និង ក្រុម៣"* អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ថ្ងៃទី២៣ ខែមិនា ឆ្នាំ ២០០៩ (E28)។

ទៅនឹងសេចក្តីបង្គាប់របស់អង្គជំនុំជម្រះដូចបានបញ្ជាក់នៅក្នុងសេចក្តីណែនាំរបស់ខ្លួន តាមរយៈឯកសារមួយដោយឡែក។

## II. សេចក្តីបញ្ជាក់របស់មេធាវីការពារ

៥. នៅក្នុងចម្លើយតបរបស់ខ្លួនចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩ ក្រុមសហមេធាវីការពារក្តី សូមសំណូមពរទៅអង្គជំនុំជម្រះសាលាដំបូងមេត្តាបដិសេធចោលពាក្យសុំបញ្ចូលខ្លួនលោកសាស្ត្រាចារ្យ **Christophe Staker** និងលោកស្រីបណ្ឌិត **Phuong Pham** ដែលឈ្មោះ សាក្សីទាំងពីរនេះត្រូវបានបញ្ចូលទៅក្នុងបញ្ជីសាក្សីរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ហើយដែលពួកគេនឹងត្រូវចូលខ្លួនទៅពិភាក្សាលើករណីនៃការសម្រេចអំពីទោស។

៦. នៅក្នុងចម្លើយតបនេះ ក្រុមសហមេធាវីការពារក្តីក៏បានស្នើសុំផងដែរទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីឱ្យអង្គជំនុំជម្រះធ្វើការប្រកាសនិងសម្រេចថា មានតែអយ្យការមួយគត់ដែលមានសិទ្ធិក្នុងការស្នើសុំឱ្យមានការដាក់ទោសក្នុងពេលសវនាការ ហើយសិទ្ធិនេះមិនត្រូវបានប្រគល់ឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

៧. ហេតុដូច្នេះហើយ ក្រុមសហមេធាវីការពារក្តីសូមធ្វើការបញ្ជាក់ថា ពាក្យសុំរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសុំឱ្យកោះហៅលោក **Robert BADINTER** នឹងត្រូវចាត់ទុកថាគ្មានកម្មវត្ថុ ប្រសិនណាបើអង្គជំនុំជម្រះសាលាដំបូងសម្រេចបដិសេធពាក្យសុំបញ្ចូលសាក្សីខាងលើ ហើយចេញសេចក្តីសម្រេចដែលបញ្ជាក់ថានៅក្នុងរឿងក្តីរបស់លោក **កាំង ហ្គេកអ៊ាវ** ភាគីដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនត្រូវអនុញ្ញាតឱ្យធ្វើការស្នើសុំអំពីការដាក់ទោសឡើយ ។

[០០១/១៨-០៧-២០០៧-អវតក/អជសជ]

628/3

# សុំរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | |
|---|---|---|
| តំណាងសហមេធាវីទាំងពីរ<br><br>មេធាវី François ROUX | ភ្នំពេញ | |
| ឈ្មោះ | ទីកន្លែង | ហត្ថលេខា |